- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-** ត្រូវបានតម្លើងឋានៈជូន ឯកឧត្តម **នូច ភានុន** ពីអគ្គលេខាធិការ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទមានឋានៈស្មើ **រដ្ឋលេខាធិការ** ទៅជាអគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដោយមានឋានៈស្មើ **រដ្ឋមន្ត្រី** វិញ ។

**មាត្រា២.-** បទប្បញ្ញត្តិចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ត្រង់មាត្រា១ ដែលមានការពាក់ព័ន្ធ នឹងឋានៈរបស់ឯកឧត្តម **នូច ភានុន** ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣.-** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

**មាត្រា៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.០៥០៧.៣៣៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ,ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៥

លេខ ៣០០៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៥២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ជា សាវឿន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៥*

Chhea Savran

លេខៈ ... ច.ល
**ដើម្បីចម្លងចេញ**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាវឌី តាន់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :៩២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០៧០៤/០០១.ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១១៧.ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤.ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤.ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ .ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣.ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ .ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក.ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

ប្រការ១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

ឯកតា : ពាន់រៀល

| ជំពូក | ការរាយមុខ | ឥណទានដើមឆ្នាំ | ចលនាឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|
| | | | កើន | ថយ | |
| | **ការផ្ទេរចេញ** | | | | |
| | **៩៩ - ចំណាយមិនទាន់បែងចែក** | - | - | 275.000.000 | - |
| ១២ | ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល | 95.000.000 | - | 95.000.000 | 0 |
| ២០ | ការប្រាក់លើការខ្ចីបុលរយៈពេលវែង មធ្យម និង ខ្លី | 50.000.000 | - | 50.000.000 | 0 |
| ៤០ | ចំណាយផ្សេងៗ | 125.805.000 | - | 80.000.000 | 45.805.000 |
| ៥៣ | ការខូចខាតបំណុល | 90.000.000 | - | 50.000.000 | 40.000.000 |
| | **ការផ្ទេរចូល** | | | | |
| | **១០ - ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | - | 275.000.000 | - | - |
| ១២ | ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល | 0 | 95.000.000 | - | 95.000.000 |
| ២១ | ការប្រាក់លើការខ្ចីបុលរយៈពេលវែង មធ្យម និង ខ្លី | 0 | 50.000.000 | - | 50.000.000 |
| ៣០ | អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច | 0 | 60.000.000 | - | 60.000.000 |
| ៤០ | ចំណាយផ្សេងៗ | 0 | 20.000.000 | - | 20.000.000 |
| ៥៣ | ការខូចខាតបំណុល | 0 | 50.000.000 | - | 50.000.000 |

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ .ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានឃើញ និងសូមគោរពជូន សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៦២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### មាត្រា ១.-

អនុក្រឹត្យនេះ មានគោលដៅបំពេញបន្ថែម និង កែប្រែប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ស្របតាមមាត្រា ២២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ដោយចាប់អនុវត្តពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ តទៅ។

**មាត្រា ២.-**

ប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលមានចែងក្នុងមាត្រា ១៧, ១៨, ១៩ និង មាត្រា ២០ ជំពូកទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ ស្តីពីការកែសំរួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង ប្រាក់កំរៃគរុកោសល្យក្នុងវិស័យអប់រំ ត្រូវកែប្រែដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ។

**មាត្រា ៣.-**

ប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញមុខងារនៅក្នុងមុខតំណែង ដូចមានកំណត់នៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ត្រូវបានកំណត់ទៅតាមវិស័យដូចខាងក្រោម :

១-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការរដ្ឋបាលទូទៅ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | អនុប្រធាននាយកដ្ឋាន | ៥៤០ ០០០៛ | ៥៧៨ ០០០៛ | ៦១៨ ០០០៛ | ៦៦១ ០០០៛ | ៧០៦ ០០០៛ |
| ២ | ប្រធានមន្ទីរជំនាញ ខេត្ត-ក្រុង | ៥២៥ ០០០៛ | ៥៦៣ ០០០៛ | ៦០៣ ០០០៛ | ៦៤៦ ០០០៛ | ៦៩១ ០០០៛ |
| ៣ | អធិការរង ថ្នាក់កណ្តាល | ៥២៥ ០០០៛ | ៥៦៣ ០០០៛ | ៦០៣ ០០០៛ | ៦៤៦ ០០០៛ | ៦៩១ ០០០៛ |
| ៤ | ប្រធាន ការិយាល័យ ថ្នាក់កណ្តាល | ៧៨ ១០០៛ | ៨៩ ៨០០៛ | ១០៣៣០០៛ | ១១៨ ៨០០៛ | ១៣៦ ៦០០៛ |
| ៥ | អនុប្រធាន មន្ទីរជំនាញខេត្តក្រុង | ៧១ ០០០៛ | ៨១ ៧០០៛ | ៩៤ ០០០៛ | ១០៨ ១០០៛ | ១២៤ ៣០០៛ |
| ៦ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ៦៥ ០០០៛ | ៧៤ ៨០០៛ | ៨៦ ០០០៛ | ៩៨ ៩០០៛ | ១១៣ ៧០០៛ |
| ៧ | អនុប្រធាន ការិយាល័យ ថ្នាក់កណ្តាល | ៦១ ៤០០៛ | ៧០ ៦០០៛ | ៨១ ២០០៛ | ៩៣ ៤០០៛ | ១០៧ ៤០០៛ |
| ៨ | ប្រធាន ការិយាល័យ មន្ទីរជំនាញខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ៩ | អនុប្រធានការិយាល័យមន្ទីរជំនាញខេត្តក្រុង | ៤៤ ១០០៛ | ៥០ ៧០០៛ | ៥៨ ៣០០៛ | ៦៧ ១០០៛ | ៧៧ ២០០៛ |
| ១០ | ប្រធាន ការិយាល័យ ជំនាញស្រុកខណ្ឌ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ | ៦៤ ០០០៛ | ៧៣ ៦០០៛ |
| ១១ | មន្ត្រីក្រមការ | ៣៦ ៥០០៛ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ | ៦៤ ០០០៛ |
| ១២ | អនុប្រធាន ការិយាល័យ ជំនាញស្រុកខណ្ឌ | ៣១ ៧០០៛ | ៣៦ ៥០០៛ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ |
| ១៣ | មន្ត្រីលេខាធិការ | ២៤ ០០០៛ | ២៧ ៦០០៛ | ៣១ ៨០០៛ | ៣៦ ៦០០៛ | ៤២ ១០០៛ |

២-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការរដ្ឋបាលមហាផ្ទៃ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | អភិបាល ស្រុកខ័ណ្ឌ | ៥៣០ ០០០៛ | ៥៦៨ ០០០៛ | ៦០៨ ០០០៛ | ៦៥១ ០០០៛ | ៦៩៦ ០០០៛ |
| ២ | នាយ ខុទ្ទកាល័យសាលាខេត្តក្រុង | ៥២៥ ០០០៛ | ៥៦៣ ០០០៛ | ៦០៣ ០០០៛ | ៦៤៦ ០០០៛ | ៦៩១ ០០០៛ |
| ៣ | អភិបាលរង ស្រុកខ័ណ្ឌ | ៧១ ០០០៛ | ៨១ ៧០០៛ | ៩៤ ០០០៛ | ១០៨ ១០០៛ | ១២៤ ៣០០៛ |
| ៤ | នាយរង ខុទ្ទកាល័យសាលាខេត្តក្រុង | ៧១ ០០០៛ | ៨១ ៧០០៛ | ៩៤ ០០០៛ | ១០៨ ១០០៛ | ១២៤ ៣០០៛ |
| ៥ | អគ្គលេខាធិការ សាលាខេត្តក្រុង | ៦៧ ៦០០៛ | ៧៧ ៨០០៛ | ៨៩ ៥០០៛ | ១០២ ៩០០៛ | ១១៨ ៣០០៛ |
| ៦ | ប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៦៧ ៦០០៛ | ៧៧ ៨០០៛ | ៨៩ ៥០០៛ | ១០២ ៩០០៛ | ១១៨ ៣០០៛ |
| ៧ | ប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៦៧ ៦០០៛ | ៧៧ ៨០០៛ | ៨៩ ៥០០៛ | ១០២ ៩០០៛ | ១១៨ ៣០០៛ |
| ៨ | អគ្គលេខាធិការរង សាលាខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ៩ | អនុប្រធានក្រុមហិរញ្ញវត្ថុ សាលាខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ១០ | អនុប្រធានក្រុមអធិការកិច្ច សាលាខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ១១ | ប្រធាន ការិយាល័យសាលាខេត្តក្រុង | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ | ៩៧ ៦០០៛ |
| ១២ | ប្រធាន មន្ទីរ សាលាស្រុកខ័ណ្ឌ | ៤៨ ៥០០៛ | ៥៥ ៨០០៛ | ៦៤ ២០០៛ | ៧៣ ៨០០៛ | ៨៤ ៩០០៛ |
| ១៣ | អនុប្រធាន ការិយាល័យសាលាខេត្តក្រុង | ៤៤ ១០០៛ | ៥០ ៧០០៛ | ៥៨ ៣០០៛ | ៦៧ ១០០៛ | ៧៧ ២០០៛ |
| ១៤ | អនុប្រធាន មន្ទីរ សាលាស្រុកខ័ណ្ឌ | ៤៤ ១០០៛ | ៥០ ៧០០៛ | ៥៨ ៣០០៛ | ៦៧ ១០០៛ | ៧៧ ២០០៛ |
| ១៥ | ប្រធាន ការិយាល័យ សាលាស្រុកខ័ណ្ឌ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ | ៦៤ ០០០៛ | ៧៣ ៦០០៛ |
| ១៦ | អនុប្រធាន ការិយាល័យ សាលាស្រុកខ័ណ្ឌ | ៣១ ៧០០៛ | ៣៦ ៥០០៛ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ |
| ១៧ | ស្មៀនឃុំសង្កាត់ | ៣១ ៧០០៛ | ៣៦ ៥០០៛ | ៤២ ០០០៛ | ៤៨ ៣០០៛ | ៥៥ ៦០០៛ |

៣-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីពន្ធនាគាររដ្ឋបាលមហាផ្ទៃ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | ប្រធានពន្ធនាគារកណ្តាល | ១២៦ ៥០០៛ | ១៤៥ ៥០០៛ | ១៦៧ ៣០០៛ | ១៩២ ៤០០៛ | ២២១ ៣០០៛ |
| ២ | អនុប្រធានពន្ធនាគារកណ្តាល | ១១៥ ០០០៛ | ១៣២ ៣០០៛ | ១៥២ ២០០៛ | ១៧៥ ០០០៛ | ២០១ ៣០០៛ |
| ៣ | ប្រធានពន្ធនាគារខេត្តក្រុង | ៩៥ ៨០០៛ | ១១០ ២០០៛ | ១២៦ ៧០០៛ | ១៤៥ ៧០០៛ | ១៦៧ ៦០០៛ |
| ៤ | អនុប្រធានពន្ធនាគារខេត្តក្រុង | ៨៧ ១០០៛ | ១០០ ២០០៛ | ១១៥ ២០០៛ | ១៣២ ៥០០៛ | ១៥២ ៤០០៛ |
| ៥ | នាយផ្នែករដ្ឋបាលពន្ធនាគារ | ៧២ ៦០០៛ | ៨៣ ៥០០៛ | ៩៦ ០០០៛ | ១១០ ៤០០៛ | ១២៧ ០០០៛ |

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ៦ | នាយរង ផ្នែករដ្ឋបាលពន្ធនាគារ | ៦៦ ០០០៛ | ៧៥ ៩០០៛ | ៨៧ ៣០០៛ | ១០០ ៤០០៛ | ១១៥ ៥០០៛ |
| ៧ | អ្នកគ្រប់គ្រងអ្នកទោសក្នុងពន្ធនាគារ | ៦០ ០០០៛ | ៦៩ ០០០៛ | ៧៩ ៤០០៛ | ៩១ ៣០០៛ | ១០៥ ០០០៛ |

## ៤-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការវិស័យអប់រំ

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ២ | នាយករង វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៣ | នាយករង វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៤ | នាយករង វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៥២០ ០០០៛ | ៥៥៨០០០៛ | ៥៩៨០០០៛ | ៦៤១០០០៛ | ៦៨៦០០០៛ |
| ៥ | នាយក សាលាមធ្យមសិក្សាបច្ចេកទេសឫស្សីកែវ | ៥២០ ០០០៛ | ៥៥៨០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៦ | សាស្ត្រាចារ្យ ឧត្តមសិក្សា | ២១៥ ៧០០៛ | ២៤៨ ១០០៛ | ២៨៥ ៣០០៛ | ៣២៨ ១០០៛ | ៣៧៧ ៣០០៛ |
| ៧ | អធិការ មធ្យមសិក្សា | ១៩៦ ១០០៛ | ២២៥ ៥០០៛ | ២៥៩ ៣០០៛ | ២៩៨ ២០០៛ | ៣៤២ ៩០០៛ |
| ៨ | គ្រូបង្រៀន ឧត្តមសិក្សា | ១៧៨ ៣០០៛ | ២០៥ ១០០៛ | ២៣៥ ៩០០៛ | ២៧១ ៣០០៛ | ៣១២ ០០០៛ |
| ៩ | នាយក វិទ្យាល័យ | ១៣២១០០៛ | ១៥១ ៩០០៛ | ១៧៤ ៧០០៛ | ២០០ ៩០០៛ | ២៣១ ០០០៛ |
| ១០ | នាយករង វិទ្យាល័យ | ១២៥ ៨០០៛ | ១៤៤ ៧០០៛ | ១៦៦ ៤០០៛ | ១៩១ ៤០០៛ | ២២០ ១០០៛ |
| ១១ | គ្រូបង្រៀន មធ្យមសិក្សា ទុតិយភូមិ | ១២៥ ៨០០៛ | ១៤៤ ៧០០៛ | ១៦៦ ៤០០៛ | ១៩១ ៤០០៛ | ២២០ ១០០៛ |
| ១២ | នាយក មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ១១៩ ៨០០៛ | ១៣៧ ៨០០៛ | ១៥៨ ៥០០៛ | ១៨២ ៣០០៛ | ២០៩ ៧០០៛ |
| ១៣ | នាយក សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |
| ១៤ | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |
| ១៥ | នាយក សាលាគរុកោសល្យខេត្តក្រុង | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |
| ១៦ | នាយក មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ១១៤ ១០០៛ | ១៣១ ២០០៛ | ១៥០ ៩០០៛ | ១៧៣ ៥០០៛ | ១៩៩ ៥០០៛ |
| ១៧ | នាយករង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ១០៨ ៧០០៛ | ១២៥ ០០០៛ | ១៤៣ ៨០០៛ | ១៦៥ ៤០០៛ | ១៩០ ២០០៛ |
| ១៨ | នាយករង សាលាមធ្យមសិក្សាបច្ចេកទេសឫស្សីកែវ | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ១៩ | នាយករង សាលាគរុកោសល្យខេត្តក្រុង | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ២០ | នាយករង សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា | ១០៣ ៥០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ២១ | នាយករងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | ១០៣ ៩០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ២២ | នាយករង មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ | ១០៣ ៩០០៛ | ១១៩ ០០០៛ | ១៣៦ ៩០០៛ | ១៥៧ ៤០០៛ | ១៨១ ០០០៛ |
| ២៣ | អធិការ បឋមសិក្សា | ៩៨ ៦០០៛ | ១១៣ ៤០០៛ | ១៣០ ៤០០៛ | ១៥០ ០០០៛ | ១៧២ ៥០០៛ |
| ២៤ | នាយក អនុវិទ្យាល័យ | ៩៣ ៩០០៛ | ១០៨ ០០០៛ | ១២៤ ២០០៛ | ១៤២ ៨០០៛ | ១៦៤ ២០០៛ |
| ២៥ | នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៩៣ ៩០០៛ | ១០៨ ០០០៛ | ១២៤ ២០០៛ | ១៤២ ៨០០៛ | ១៦៤ ២០០៛ |
| ២៦ | នាយករង អនុវិទ្យាល័យ | ៨៩ ៤០០៛ | ១០២ ៨០០៛ | ១១៨ ២០០៛ | ១៣៥ ៩០០៛ | ១៥៦ ៣០០៛ |
| ២៧ | នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តក្រុង | ៨៩ ៤០០៛ | ១០២ ៨០០៛ | ១១៨ ២០០៛ | ១៣៥ ៩០០៛ | ១៥៦ ៣០០៛ |
| ២៨ | គ្រូបង្រៀន មធ្យមសិក្សា បឋមភូមិ | ៨៥ ១០០៛ | ៩៧ ៩០០៛ | ១១២ ៦០០៛ | ១២៩ ៥០០៛ | ១៤៨ ៩០០៛ |
| ២៩ | នាយក សាលាបឋមសិក្សា-មត្តេយ្យសិក្សា | ៨១ ០០០៛ | ៩៣ ២០០៛ | ១០៧ ២០០៛ | ១២៣ ៣០០៛ | ១៤១ ៨០០៛ |
| ៣០ | នាយករង សាលាបឋមសិក្សា-មត្តេយ្យសិក្សា | ៧៣ ៦០០៛ | ៨៤ ៧០០៛ | ៩៧ ៤០០៛ | ១១២ ០០០៛ | ១២៨ ៨០០៛ |
| ៣១ | គ្រូបង្រៀន បឋមសិក្សា-មត្តេយ្យសិក្សា | ៧០ ១០០៛ | ៨០ ៦០០៛ | ៩២ ៧០០៛ | ១០៦ ៦០០៛ | ១២២ ៦០០៛ |
| ៣២ | គ្រូបង្រៀន កំរិត បឋម | ៦៨ ០០០៛ | ៧៨ ២០០៛ | ៨៩ ៩០០៛ | ១០៣ ៤០០៛ | ១១៨ ៩០០៛ |

៥-តារាងប្រាក់បំណាច់មុខងារប្រចាំខែរបស់មន្ត្រីរាជការវិស័យសុខាភិបាល

| ល.រ | មុខងារ | កំរិត ៥ | កំរិត ៤ | កំរិត ៣ | កំរិត ២ | កំរិត ១ |
|---|---|---|---|---|---|---|
| ១ | ព្រឹទ្ធបុរសរង មហាវិទ្យាល័យ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ២ | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រថ្នាក់កណ្តាល | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៣ | នាយករង មន្ទីរពេទ្យជាតិ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៤ | នាយករង មជ្ឈមណ្ឌលជាតិ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៥ | នាយករង វិទ្យាស្ថានជាតិ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៦ | នាយករង មន្ទីរពិសោធន៍ត្រួតពិនិត្យគុណភាពឱសថ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៧ | នាយករង ឃ្លាំងឱសថកណ្តាល | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៨ | នាយក សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៥២០ ០០០៛ | ៥៥៨ ០០០៛ | ៥៩៨ ០០០៛ | ៦៤១ ០០០៛ | ៦៨៦ ០០០៛ |
| ៩ | គ្រូពេទ្យ ឯកទេស | ២០៣ ៨០០៛ | ២៣៤ ៤០០៛ | ២៦៩ ៦០០៛ | ៣១០ ១០០៛ | ៣៥៦ ៦០០៛ |
| ១០ | គ្រូពេទ្យ-អនុបណ្ឌិត | ១៨៥ ៣០០៛ | ២១៣ ១០០៛ | ២៤៥ ១០០៛ | ២៨១ ៩០០៛ | ៣២៤ ២០០៛ |
| ១១ | ទន្តបណ្ឌិតឯកទេស | ១៧៦ ៥០០៛ | ២០៣ ០០០៛ | ២៣៣ ៥០០៛ | ២៦៨ ៥០០៛ | ៣០៨ ៨០០៛ |
| ១២ | ឱសថបណ្ឌិត | ១៧៦ ៥០០៛ | ២០៣ ០០០៛ | ២៣៣ ៥០០៛ | ២៦៨ ៥០០៛ | ៣០៨ ៨០០៛ |

| ល.រ | មុខងារ | កាំរិត ៥ | កាំរិត ៤ | កាំរិត ៣ | កាំរិត ២ | កាំរិត ១ |
|---|---|---|---|---|---|---|
| ១៣ | គ្រូពេទ្យ ការពារ | ១៤៧ ១០០៛ | ១៦៩ ២០០៛ | ១៩៤ ៦០០៛ | ២២៣ ៨០០៛ | ២៥៧ ៤០០៛ |
| ១៤ | ឱសថការី ការពារ | ១៤៧ ១០០៛ | ១៦៩ ២០០៛ | ១៩៤ ៦០០៛ | ២២៣ ៨០០៛ | ២៥៧ ៤០០៛ |
| ១៥ | គ្រូពេទ្យ ព្យាបាល | ១៣៣ ៧០០៛ | ១៥៣ ៨០០៛ | ១៧៦ ៩០០៛ | ២០៣ ៤០០៛ | ២៣៣ ៩០០៛ |
| ១៦ | ឱសថការី ព្យាបាល | ១៣៣ ៧០០៛ | ១៥៣ ៨០០៛ | ១៧៦ ៩០០៛ | ២០៣ ៤០០៛ | ២៣៣ ៩០០៛ |
| ១៧ | ទន្តបណ្ឌិត | ១៣៣ ៧០០៛ | ១៥៣ ៨០០៛ | ១៧៦ ៩០០៛ | ២០៣ ៤០០៛ | ២៣៣ ៩០០៛ |
| ១៨ | គ្រូពេទ្យ មធ្យម | ១១១ ៤០០៛ | ១២៨ ១០០៛ | ១៤៧ ៣០០៛ | ១៦៩ ៤០០៛ | ១៩៤ ៨០០៛ |
| ១៩ | ទន្តពេទ្យ មធ្យម | ១១១ ៤០០៛ | ១២៨ ១០០៛ | ១៤៧ ៣០០៛ | ១៦៩ ៤០០៛ | ១៩៤ ៨០០៛ |
| ២០ | ឱសថការី មធ្យម | ១១១ ៤០០៛ | ១២៨ ១០០៛ | ១៤៧ ៣០០៛ | ១៦៩ ៤០០៛ | ១៩៤ ៨០០៛ |
| ២១ | នាយករង សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ១០១ ៣០០៛ | ១១៦ ៥០០៛ | ១៣៤ ០០០៛ | ១៥៤ ១០០៛ | ១៧៧ ២០០៛ |
| ២២ | ប្រធានការិ. ស្រុកប្រតិបត្តិ | ៩២ ១០០៛ | ១០៥ ៩០០៛ | ១២១ ៨០០៛ | ១៤០ ១០០៛ | ១៦១ ១០០៛ |
| ២៣ | អនុប្រធានការិ. ស្រុកប្រតិបត្តិ | ៨៣ ៧០០៛ | ៩៦ ៣០០៛ | ១១០ ៨០០៛ | ១២៧ ៤០០៛ | ១៤៦ ៥០០៛ |
| ២៤ | ប្រធាន មន្ទីរពេទ្យបង្អែក | ៧៦ ១០០៛ | ៨៧ ៥០០៛ | ១០០ ៦០០៛ | ១១៥ ៧០០៛ | ១៣៣ ១០០៛ |
| ២៥ | អនុប្រធាន មន្ទីរពេទ្យបង្អែក | ៦៩ ២០០៛ | ៧៩ ៦០០៛ | ៩១ ៦០០៛ | ១០៥ ៤០០៛ | ១២១ ២០០៛ |
| ២៦ | ប្រធាន មណ្ឌលសុខភាព | ៦២ ៩០០៛ | ៧២ ៣០០៛ | ៨៣ ២០០៛ | ៩៥ ៧០០៛ | ១១០ ១០០៛ |
| ២៧ | អនុប្រធាន មណ្ឌលសុខភាព | ៥៧ ២០០៛ | ៦៥ ៨០០៛ | ៧៥ ៧០០៛ | ៨៧ ១០០៛ | ១០០ ២០០៛ |
| ២៨ | ឆ្មប មធ្យម | ៥២ ០០០៛ | ៥៩ ៨០០៛ | ៦៨ ៨០០៛ | ៧៩ ១០០៛ | ៩១ ០០០៛ |
| ២៩ | គិលានុបដ្ឋាក មធ្យម | ៥២ ០០០៛ | ៥៩ ៨០០៛ | ៦៨ ៨០០៛ | ៧៩ ១០០៛ | ៩១ ០០០៛ |
| ៣០ | អ្នកព្យាបាលដោយចលនា មធ្យម | ៥២ ០០០៛ | ៥៩ ៨០០៛ | ៦៨ ៨០០៛ | ៧៩ ១០០៛ | ៩១ ០០០៛ |
| ៣១ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍ មធ្យម | ៥២ ០០០៛ | ៥៩ ៨០០៛ | ៦៨ ៨០០៛ | ៧៩ ១០០៛ | ៩១ ០០០៛ |
| ៣២ | អ្នកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម | ៤០ ០០០៛ | ៤៦ ០០០៛ | ៥២ ៩០០៛ | ៦០ ៨០០៛ | ៦៩ ៩០០៛ |
| ៣៣ | ឆ្មប បឋម | ៤០ ០០០៛ | ៤៦ ០០០៛ | ៥២ ៩០០៛ | ៦០ ៨០០៛ | ៦៩ ៩០០៛ |
| ៣៤ | គិលានុបដ្ឋាក បឋម | ៤០ ០០០៛ | ៤៦ ០០០៛ | ៥២ ៩០០៛ | ៦០ ៨០០៛ | ៦៩ ៩០០៛ |
| ៣៥ | អ្នកព្យាបាលដោយចលនា បឋម | ៤០ ០០០៛ | ៤៦ ០០០៛ | ៥២ ៩០០៛ | ៦០ ៨០០៛ | ៦៩ ៩០០៛ |
| ៣៦ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍ បឋម | ៤០ ០០០៛ | ៤៦ ០០០៛ | ៥២ ៩០០៛ | ៦០ ៨០០៛ | ៦៩ ៩០០៛ |

**មាត្រា ៨.-**

មន្ត្រីពន្ធនាគាររបស់រដ្ឋបាលមហាផ្ទៃ ត្រូវបានផ្ដល់ជូនប្រាក់ម្ហូប និងថ្លៃអង្ករបន្ថែមប្រចាំខែ សរុបចំនួន៧២ ០០០៛ ក្នុងមួយនាក់ ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ។

មាត្រា ៧.-

អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ៧ ឆ្នាំ ២០០៥

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល**

**សុខ អាន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៩៧...អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពី

## ការប្ដូរឈ្មោះ " វិទ្យាស្ថានអាស៊ីប៉ាស៊ីហ្វិច ទៅជា វិទ្យាស្ថានប៊ែលធីអន្តរជាតិ "

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/0៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមនស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្ដីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២០ខែមករា ឆ្នាំ២០០២ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# **សម្រេច**

**មាត្រា ១.-** ត្រូវបានអនុញ្ញាតអោយប្តូរឈ្មោះ **វិទ្យាស្ថានអាស៊ីប៉ាស៊ីហ្វិច** " ASIA PACIFIC INSTITUTE " ហៅកាត់ជាភាសាខ្មែរ " វ.អ.ប " ទៅជា " **វិទ្យាស្ថាន ប៊ែលធីអន្តរជាតិ** " " BELTEI INTERNATIONAL INSTITUTE " ដែលមានទីតាំងគោល នៅអាគារលេខ ១៨៩ វិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង នាយក **វិទ្យាស្ថាន ប៊ែលធីអន្តរជាតិ** ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៩៨....អនក្រ.បក

ជាតិ សាសនា ព្រះមហាក្សត្រ

## អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តប្រាក់លាភការបន្ថែម ដោយផ្អែកលើលទ្ធផលការងារ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦ /នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ

-បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត និង ដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

-យោងតាមស្មារតីនៃអង្គប្រជុំអន្តរក្រសួង កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៥

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងធ្វើការណែនាំឱ្យអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារសំរាប់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញការងារនៅតាមគំរោងផ្សេងៗរបស់ក្រសួង-ស្ថាប័ន ដែលធ្វើហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ដើម្បីឱ្យមានភាពរលូន និង ឆ្លើយតបទៅនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ២

## លក្ខខ័ណ្ឌនៃការអនុវត្ត

**មាត្រា ២.-**

ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ដែលធ្វើហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ មិនត្រូវចាត់ទុកជាប្រាក់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលទេ ។

**មាត្រា ៣.-**

ក្រសួង ស្ថាប័នទាំងអស់ ត្រូវចាត់វិធានការ និង ជំរុញលើកទឹកចិត្តដៃគូអភិវឌ្ឍន៍ទាំងអស់ ឱ្យបង្វែរប្រាក់ឧបត្ថម្ភបន្ថែមប្រចាំខែ ដែលកំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះ មកគាំទ្រដល់ការអនុវត្តគំរោងកន្សោមអាទិភាពនៅតាមក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុងនីមួយៗ ក្នុងរូបភាព ២ ដូចខាងក្រោម :

- ជួយបង្កើនចំនួនសមាជិកកន្សោមអាទិភាព ក្នុងវិស័យអាទិភាពពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ និង ការងារកំណែទំរង់រដ្ឋ ដែលការអនុវត្តចាំបាច់ត្រូវគោរពតាមគោលការណ៍ និង យន្តការនៃកម្មវិធីកន្សោមអាទិភាព ។
- ក្នុងករណីចាំបាច់ ដោយមានការពិគ្រោះយោបល់ជាមួយនឹងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និង មានការឯកភាពពីដៃគូអភិវឌ្ឍន៍ មន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅក្នុងគំរោងទាំងនោះ អាចទទួលបានប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ក្នុង ១ ខែ តាមចំនួន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| -ថ្នាក់អគ្គនាយក | ត្រូវទទួលបានចំនួន | ១.៦០០.០០០ | រៀល |
| -ថ្នាក់អគ្គនាយករង | ត្រូវទទួលបានចំនួន | ១.២៨០.០០០ | រៀល |
| -ថ្នាក់ប្រធាននាយកដ្ឋាន | ត្រូវទទួលបានចំនួន | ១.០៨០.០០០ | រៀល |
| -ថ្នាក់អនុប្រធាននាយកដ្ឋាន | ត្រូវទទួលបានចំនួន | ៨៨០.០០០ | រៀល |
| -ថ្នាក់មន្ត្រីគ្រប់គ្រងរដ្ឋបាល | ត្រូវទទួលបានចំនួន | ៧២០.០០០ | រៀល |
| -ថ្នាក់ប្រធានការិយាល័យ | ត្រូវទទួលបានចំនួន | ៤៨០.០០០ | រៀល |
| -ថ្នាក់អនុប្រធានការិយាល័យ | ត្រូវទទួលបានចំនួន | ៣៨៤.០០០ | រៀល |
| -ថ្នាក់មន្ត្រីក្រមការ | ត្រូវទទួលបានចំនួន | ៣២០.០០០ | រៀល |
| -ថ្នាក់លេខាធិការ | ត្រូវទទួលបានចំនួន | ២០០.០០០ | រៀល ។⁄. |

**មាត្រា ៤.-**

ការប្រើប្រាស់ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវបញ្ចប់ នៅពេលដែលការធ្វើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ត្រូវបានបញ្ចប់ ឬ គំរោងត្រូវបានបញ្ចប់។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**បានយកសេចក្តីជម្រាបជូនសម្តេច នាយករដ្ឋមន្ត្រី**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

និងជា ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- អគ្គស្នងការដ្ឋានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ

សេចក្តីព្រាង

# តារាង បៀវត្ស ~ ប្រាក់បំណាច់មុខងារ និង កន្សោមអាទិភាព

| មុខងារ | ក្របខ័ណ្ឌ | បៀវត្សមូលដ្ឋាន | | ប្រាក់បំណាច់មុខងារ | | PMG | សរុបជារៀល | | សរុបជាដុល្លារ | | ប្រាក់បន្ថែមពីគំរោងផ្សេងៗ | សរុបទូទៅ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | Min. | Max. | Min. | Max. | | Min. | Max. | Min. | Max. | | Min. | Max. |
| អគ្គនាយក | ក១ | 150,420 | 189,750 | 735,000 | 929,000 | 0 | 885,420 | 1,118,750 | 221 $ | 279 $ | 400 $ | 621 $ | 679 $ |
| អគ្គនាយករង | ក២ | 124,545 | 168,015 | 645,000 | 815,000 | 0 | 769,545 | 983,015 | 192 $ | 245 $ | 320 $ | 512 $ | 565 $ |
| ប្រធាននាយកដ្ឋាន | ក២ | 124,545 | 168,015 | 620,000 | 786,000 | 0 | 744,545 | 954,015 | 186 $ | 238 $ | 270 $ | 456 $ | 508 $ |
| អនុប្រធាននាយកដ្ឋាន | ក៣ | 108,675 | 146,625 | 540,000 | 706,000 | 0 | 648,675 | 852,625 | 162 $ | 213 $ | 220 $ | 382 $ | 433 $ |
| មន្ត្រីគ្រប់គ្រងរដ្ឋបាល | ក៣ | 108,675 | 146,625 | 65,000 | 113,700 | 520,000 | 693,675 | 780,325 | 173 $ | 195 $ | 180 $ | 353 $ | 375 $ |
| ប្រធានការិយាល័យ | ខ១ | 106,260 | 132,825 | 78,100 | 136,600 | 350,000 | 534,360 | 619,425 | 133 $ | 154 $ | 120 $ | 253 $ | 274 $ |
| អនុប្រធានការិយាល័យ | ខ២ | 86,940 | 117,300 | 61,400 | 107,400 | 350,000 | 498,340 | 574,700 | 124 $ | 143 $ | 96 $ | 220 $ | 239 $ |
| មន្ត្រីក្រមការ | ខ៣ | 73,900 | 102,465 | 36,500 | 64,000 | 350,000 | 460,400 | 516,465 | 115 $ | 129 $ | 80 $ | 195 $ | 209 $ |
| នាយលេខាធិការ | គ១ | 73,140 | 90,390 | 24,000 | 42,100 | 190,000 | 287,140 | 322,490 | 71 $ | 80 $ | 50 $ | 121 $ | 130 $ |
| លេខាធិការដើមខ្សែ | គ២ | 59,685 | 80,385 | 24,000 | 42,100 | 190,000 | 273,685 | 312,485 | 68 $ | 78 $ | 50 $ | 118 $ | 128 $ |
| លេខាធិការ | គ៣ | 51,750 | 69,690 | 24,000 | 42,100 | 190,000 | 265,750 | 301,790 | 66 $ | 75 $ | 50 $ | 116 $ | 125 $ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សាកលវិទ្យាល័យ ស៊ីធី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំរបស់ លោក ហ៊ិន ហាវ័ណ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៥
- បានឃើញលិខិតលេខ ២៣១៩ អយក.ឧស ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥ របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យ ស៊ីធី** ( City University ) ហៅកាត់ជាភាសាខ្មែរ " ស.ស " និងហៅកាត់ជាភាសាអង់គ្លេស " C.U "។ សាកលវិទ្យាល័យ នេះ មានទីតាំងស្ថិតនៅ អគារលេខ ១១៩ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**មាត្រា ២ :** សាកលវិទ្យាល័យ ស៊ីធី មានតួនាទីជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលធនធានមនុស្ស និងស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣ :** សាកលវិទ្យាល័យ ស៊ីធី ធ្វើការបណ្ដុះបណ្ដាលកម្រិត :

-ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេល ២ឆ្នាំ ត្រូវនឹង ៧០ក្រេឌីត ជាមធ្យម

-ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេល ៤ឆ្នាំ ត្រូវនឹង ១៤០ក្រេឌីត ជាមធ្យម

-ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ សិក្សារយៈពេល ២ឆ្នាំ ត្រូវនឹង ៥៤ក្រេឌីត ជាមធ្យម

-ថ្នាក់បណ្ឌិត សិក្សាស្រាវជ្រាវរយៈពេល ៣ឆ្នាំ

សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤ :** ក្នុងដំណើរការចាប់ផ្ដើមនេះ សាកលវិទ្យាល័យ ស៊ីធី មានមហាវិទ្យាល័យ ចំនួន ០៥ គឺ :

១-មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា : ឯកទេសអក្សរសាស្ត្រអង់គ្លេស

២-មហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ : ឯកទេសវិទ្យាសាស្ត្រកុំព្យូទ័រ អគ្គិសនី និងអេឡិចត្រូនិច

៣-មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម : ឯកទេសសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយ

៤-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ : ឯកទេសគ្រប់គ្រង គណនេយ្យ ទីផ្សារ ហិរញ្ញវត្ថុ គ្រប់គ្រងទេសចរណ៍ និងគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ

៥-មហាវិទ្យាល័យនីតិសាស្ត្រ : ឯកទេសនីតិសាស្ត្រ

ទៅអនាគត សាកលវិទ្យាល័យ ស៊ីធី អាចពង្រីក ឬប្ដូរទីតាំង បើកមហាវិទ្យាល័យ សាខា ឯកទេស និងប្រភេទបណ្ដុះបណ្ដាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥ :** សាកលវិទ្យាល័យ ស៊ីធី ដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ ដែលមានភារកិច្ចអនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ។

**មាត្រា ៦ :** សាកលវិទ្យាល័យ ស៊ីធី ត្រូវអនុវត្តតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាល ដែលបានកំណត់លើសកម្មភាព ដើម្បីធានាគុណភាពនៃការបណ្ដុះបណ្ដាល។

**មាត្រា ៧ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្ដែង របស់សាកលវិទ្យាល័យ ស៊ីធី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ស៊ីធី មានភារកិច្ចទទួលខុសត្រូវ ចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ហើយនិងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៩ :** និស្សិតដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យ ស៊ីធី និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សានោះ ត្រូវទទួលបានសញ្ញាប័ត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ ស៊ីធី ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យ បំពេញ និងអនុវត្តបានតាមគោលការណ៍កំណត់របស់ ក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ១០ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យ ស៊ីធី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៣២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

១-ព្រះតេជគុណ **ឃន សុវណ្ណារ៉ា** ព្រះចៅអធិការវត្តកំពង់ពោធិ៍ ជួយកសាងព្រះវិហារ ០១ខ្នង នៅវត្តកំពង់ពោធិ៍ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ចំណាយអស់បច្ច័យចំនួន ១០.៩៥០ ដុល្លារ ។

២-លោក **ឆឹង នង** នៅសហរដ្ឋអាមេរិក ជួយកសាងសាលាបាលី ០១ខ្នង នៅវត្តប្រាសាទស្វាយព្រៃ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ថវិកាចំនួន ១៨.៨៧១.៦២ ដុល្លារ ។

៣-លោក **កែវ សុខា** និង អ្នកស្រី **សោម យ៉ុន** កសាងកុដិ ០១ខ្នង នៅវត្តប្រាសាទស្វាយព្រៃ ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ថវិកាចំនួន ១២.៦០០ ដុល្លារ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

PS59

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៦៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគថវិកាចូលរួមកសាងសមិទ្ធផល នៅក្នុងស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ :-

១-ឧបាសក **ទេព ខៀត** ឪពុកឯកឧត្តម **ទេព ខន** ជួយកសាង សាលាធម្មសភា ០១ខ្នង ចំណាយអស់ថវិកា ចំនួន ៥០.០០០ ដុល្លារ ។

២-លោក **មូរ៉ា កាមី** នៅទីក្រុង អូសាកា ប្រទេសជប៉ុន

៣-លោកស្រី **មូរ៉ា កាមី** នៅទីក្រុង អូសាកា ប្រទេសជប៉ុន

លោក និង លោកស្រី ទាំង០២រូប បានជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ នៅ វត្តភូមិគរ ឃុំអង្គខ្នុរ ចំណាយអស់ថវិកា ចំនួន ២៤.០០០ ដុល្លារ ។

៤-លោក **តាកេស៊ី យូកាវ៉ា** នៅទីក្រុង អូសាកា ប្រទេសជប៉ុន

៥-លោកស្រី **តាកេស៊ី យូកាវ៉ា** នៅទីក្រុង អូសាកា ប្រទេសជប៉ុន

លោក និង លោកស្រី ទាំង០២រូប បានជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ នៅវត្តពោធិអំពិល ឃុំសំបួរ ចំណាយអស់ថវិកា ចំនួន ២៤.០០០ ដុល្លារ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ [illegible] ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Ps-122

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ:...៦៣៣...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគថវិកា ជួយកសាងអគារសិក្សា ០៣ខ្នង មាន១៤បន្ទប់ បំពាក់សំភារៈសិក្សាគ្រប់គ្រាន់ ធ្វើខ្លោងទ្វារសាលា បង្គន់អនាម័យ និង អណ្តូងទឹក ពាក់កណ្តាលស្វ័យប្រវត្តិ នៅអនុវិទ្យាល័យសែប ឃុំសែប និងសាលាបឋមសិក្សាត្រពាំងក្ការ ឃុំថ្មឥដ្ឋ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ :-

១-អង្គការ AICHI BUDDHIST Federation (ជប៉ុន) ថវិកាចំនួន ៧២.០៣០ ដុល្លារ

២-អង្គការ **មូលនិធិរំលឹកគុណ ខិមរ៉ាត់សាឌី ដើម្បីលទ្ធិប្រជាធិបតេយ្យ** ថវិកាចំនួន ១១.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៸

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ... ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល</u> :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

PS55

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៤គ្រឿង ជូនសមាគម និង សប្បុរសជនជប៉ុន ដែលបានផ្តល់ថវិកា ជួយសាងសង់អាគារសិក្សា០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ របង និង ខ្លោងទ្វារ នៅសាលាបឋមសិក្សា សមរមេត្រី ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-TAKAHASHI ROTARY CLUB | | ថវិកាចំនួន ១០.៦០០ ដុល្លារ |
| ២-NIMI ROTARY CLUB | | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ៣-SOROPTIMIST INTERNATIONAL TAKAHASHI | | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ៤-NUORN BUNPHAL | សប្បុរសជននៅប្រទេសជប៉ុន | ថវិកាចំនួន ១០.៥០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.78

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៤

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ឈា ស្រេង** សប្បុរសជនខ្មែរ រស់នៅប្រទេសបារាំង ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា មួយខ្នង បំពាក់ដោយសម្ភារីមគ្រប់ប្រភេទ ស្ថិតនៅក្នុងឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ចំណាយអស់ទឹកប្រាក់ចំនួន **១២.**៨៤០ ដុល្លារ ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

SR.86

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៣៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ និងស្ថានទូត ដែលបានជួយកសាងសមិទ្ធផលនៅក្នុងខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ :-

១-អង្គការ LWF បានជួយកសាងអគារសិក្សា០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០៥បន្ទប់ ខ្លោងទ្វារ និងបំពាក់សំភារៈសិក្សាគ្រប់គ្រាន់ នៅសាលាបឋមសិក្សាសាន់ប៉ាយ ឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ចំណាយអស់ទឹកប្រាក់ចំនួន ២៤.២៤៧ ដុល្លារ ។

២-*ស្ថានឯកអគ្គរាជទូតជប៉ុន* ប្រចាំព្រះរាជាណាចក្រកម្ពុជា បានជួយកសាងអគារពេទ្យរបេង ០១ខ្នង បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ និង ជួសជុលអគារសំរាប់ព្យាបាលជម្ងឺ ០១ខ្នង នៅមន្ទីរពេទ្យបង្អែកស្រុកកំពង់ត្រឡាច ចំណាយអស់ទឹកប្រាក់ ចំនួន ៥១.០៥២ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ៧ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PS57

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ....១៣៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន ចំនួន១៨រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងព្រះវិហារថ្មី សាលាធម្មសភា កុដិ សាលារៀន និងសមិទ្ធផលនានាជាច្រើនទៀត នៅវត្តទីឃវនារាម ហៅវត្ត កូនខ្លុង ឃុំព្រៃតូច ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :-

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ម៉ិច ម៉ុន** | ចៅអធិការវត្តទីឃវនារាម | បច្ច័យ ១១.២២០ ដុល្លារ |
| ២-ឧបាសក | **ហ្វូច សៅ** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកា ១៣.៦៩១ ដុល្លារ |
| ៣-លោក | **កខ គួ** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកា ១២.៤៣៦ ដុល្លារ |
| ៤-លោក | **អ៊ុំ អៀម** | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកា ១១.២៦០ ដុល្លារ |
៨_លោកស្រី **កេត ម៉ារឌី** អោយបំពេញមុខងារជាប្រធាននាយកដ្ឋានការពារផ្លូវច្បាប់

៩_លោកស្រី **ហ៊ូ និរមិត្តា** អោយបំពេញមុខងារជាប្រធាននាយកដ្ឋានស្ត្រី និង សុខភាព

១០_កញ្ញា **ឡុង និមល** អោយបំពេញមុខងារជាប្រធាននាយកដ្ឋានស្ត្រី និង ការអប់រំ

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...៧៥៧...អនក្រ - គស

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំក្រសួង នគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន០៥រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ រឹតចំណងមិត្តភាព និងជួយក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោមនេះ :-

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឡេ ហុងអាញ់** ( LE HONG ANG )

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា :**

១-ឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង **ង្វៀង ខាញ់តាន់** ( NGUYEN KHANH TOAN )

២-ឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង **ឡេ ថេទៀម** ( LE THE TIEM )

៣-ឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង **ង្វៀង វ៉ាន់ហឿង** ( NGUYEN VAN HUONG )

៤-ឯកឧត្តម ឧត្តមសេនីយ៍ឯកបំរុង **ង្វៀង វ៉ាន់ទិន** ( NGUYEN VAN TINH )

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Px-161

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមក្រុមហ៊ុនអគ្គិសនីកម្ពុជា

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រឹតលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រុមហ៊ុនអគ្គិសនីកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បកចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ១៩៩៦ ស្តីពីការកំណត់ពីទំនាក់ទំនងរវាងរដ្ឋាភិបាល និង អគ្គិសនីកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ១៧៣ អនក្រ.តត ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមក្រុមហ៊ុនអគ្គិសនីកម្ពុជា ។
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** តែងតាំង លោក **ឃាង វេន:** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមក្រុមហ៊ុន **អគ្គិសនីកម្ពុជា** សំរាប់អាណត្តិ ៣ ឆ្នាំ ជំនួសលោក **ភាំង លាងខំណា** ដែលបានចូលនិវត្តិន៍ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រុមហ៊ុន អគ្គិសនីកម្ពុជា
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែរ ០៣រូប រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធាន ជួយកសាងអគារសិក្សា ០១ខ្នង បង្គន់អនាម័យ អណ្តូងទឹក និងរបងសាលាបឋមសិក្សា ភូមិគោល ឃុំស្វាយអង្គ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

- ឧបាសិកា **ជាវ អេឌលី** ព្រមទាំងសប្បុរសជននៅទីក្រុងអូកឡិន រដ្ឋកាលីហ្វូនីញ៉ា ថវិកា១១.២០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ខែល ម៉ាន** ព្រមទាំងសប្បុរសជននៅ រដ្ឋចចា ថវិកាចំនួន ៦.១០០ ដុល្លារ

២-លោកស្រី **ហ៊ុច ម៉ាលីនដា** ថវិកាចំនួន ៥.៣០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.97

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៦១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក UESHIMA JUNNOSUKE ដែលបានឧបត្ថម្ភថវិកា ចំនួន ៣១.៦៥០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ០១ខ្នង មាន០៤បន្ទប់ អណ្តូងទឹក ០១ ព្រមទាំងបំពាក់សម្ភារីមគ្រប់ប្រភេទ នៅសាលាបឋមសិក្សាបុប្ផាវតី ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.91

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៦២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី NOGUCHI zHIZUKO សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកា តាមរយៈអង្គការ JHP នូវទឹកប្រាក់ចំនួន ៣១.៩៣០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ អណ្តូងទឹក ០១ សម្ភារៈកំសាន្តរបស់សិស្សានុសិស្ស ព្រមទាំងបំពាក់សង្ហារឹមគ្រប់ប្រភេទ នៅសាលាបឋមសិក្សាពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

SR.93

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១៖** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី KODAMA HIDEKO សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកា ចំនួន ៣២.៧៦៥ ដុល្លារអាមេរិក តាមរយៈអង្គការ JHP សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ និងបង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ នៅសាលាបឋមសិក្សាក្រាំងព្រៃផ្តៅ ក្នុងឃុំក្រាំងតាយ៉ង ស្រុកពាមជរ ខេត្តព្រៃវែង ។

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.89

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....៧៩៤.........អនក្រ.សរ - ធក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **សៃហ្វុល រីហ្សាល** ( SYAIFUL RIZAL ) មេបញ្ជាការកងទ័ពពិសេស នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ និងលើកស្ទួយទំនាក់ទំនងមិត្តភាព រវាងកងទ័ពពិសេស នៃប្រទេសទាំងពីរកម្ពុជា-ឥណ្ឌូណេស៊ី ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ៧ ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.139 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៧៦៥...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជាកិច្ចបច្ឆាមរណៈ ប្រគេនចំពោះសព ព្រះតេជគុណធម្មសារៈ **សម សុន** ព្រះគ្រូចៅអធិការវត្តអ្នកឡិន នៅសហរដ្ឋអាមេរិក ដែលមានស្នាព្រះហស្តល្អ និង គុណបំណាច់ខ្ពស់ក្នុងការជួយទ្រទ្រង់វិស័យព្រះពុទ្ធសាសនា ផ្នែកមនុស្សធម៌ និងសង្គមកិច្ច ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលខេត្តតាកែវ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤៧ ស.ស.រ.

**សេចក្តីសំរេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំ**
**រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើកទី ១០ និងកិច្ចប្រជុំពាក់ព័ន្ធ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ១:** បង្កើតគណៈកម្មការសំរាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើកទី១០ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលប្រារព្ធធ្វើនៅខេត្ត សៀមរាប ចាប់ពីថ្ងៃទី ០២ ដល់ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៦ មានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោកជំទាវ **នាវ ច័ន្ទថាណា** | អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **យុ. ស៊ុនឡុង** | អគ្គនាយករងនគរបាលជាតិក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥- ឯកឧត្តម **ហោ សុធន** | អគ្គលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- ឯកឧត្តម **គីម គុណាវឌ្ឍន៍** | អគ្គនាយកក្រសួងពត៌មាន | សមាជិក |

៧- ឯកឧត្តម **ស៊ីម សុន** អភិបាលខេត្តសៀមរាប សមាជិក

**ប្រការ២** : នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និង អាស៊ាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា លេខាធិការដ្ឋាន របស់គណៈកម្មការរៀបចំកិច្ចប្រជុំខាងលើនេះ ។

**ប្រការ៣** : គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ ÷

ក- រៀបចំកម្មវិធីប្រជុំ និងពិធីការអោយបានសមស្រប

ខ- រៀបចំគំរោងចំណាយសំរាប់រៀបចំកិច្ចប្រជុំខាងលើ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល

គ- សំរបសំរួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំអោយមានសុវត្ថិភាព

ឃ- ចាត់ចែងការសំដែងសិល្បៈប្រពៃណី ជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងភាគរៈអន្តរជាតិ

ង- សំរបសំរួល និងចាត់ចែងការធ្វើដំណើរទស្សនាចរជូនគណៈប្រតិភូ ក្រោយកិច្ចប្រជុំ តាមកម្មវិធីដែលបានគ្រោងទុក

ច- សំរបសំរួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយពីកិច្ចប្រជុំនេះ ។

**ប្រការ៤** : ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានាមកចូលរួមប្រជុំដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់ ។

**ប្រការ៥** : ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងៗតាមការចាំបាច់ ។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៥

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និងប្រការ៦
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៦៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ

## ត្រួតពិនិត្យ និងវាយតំលៃ ដើម្បីបង្ក្រាបសកម្មភាពឈូសឆាយ ការឈូសឆាយ ចាក់ដីបំពេញលើដីចំណីឆ្នេរសមុទ្រ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំរេច

**ប្រការ១:** បង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតំលៃ ដើម្បីបង្ក្រាបសកម្មភាពទន្ទ្រានដីព្រៃកោងកាង ការឈូសឆាយ ចាក់ដីបំពេញលើដីចំណីឆ្នេរសមុទ្រ ដែលបង្កការប៉ះពាល់យ៉ាងខ្លាំងលើស្ថានភាពរូបសាស្ត្រ អេកូឡូស៊ី តំបន់ទេសភាព ការបំផ្លាញបរិស្ថានតំបន់ឆ្នេរសមុទ្រ ។

**ប្រការ២:** គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២-រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៣-រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤- រដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៦-អភិបាលក្រុងព្រះសីហនុ | សមាជិក |
| ៧-អភិបាលក្រុងកែប | សមាជិក |
| ៨-អភិបាលខេត្តកំពត | សមាជិក |
| ៩-អភិបាលខេត្តកោះកុង | សមាជិក |
| ១០-អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន | លេខាធិការ |
| ១១-ប្រធានសំរបសំរួលតំបន់ឆ្នេរសមុទ្រ ក្រសួងបរិស្ថាន | លេខាប្រចាំការ |

**ប្រការ៣:** គណៈកម្មការនេះមានតួនាទី និងភារៈកិច្ចដូចខាងក្រោម:

- ត្រួតពិនិត្យ និងវាយតំលៃរាល់សកម្មភាពទន្ទ្រានដីព្រៃកោងកាង ការឈូសឆាយ និងចាក់ដីបំពេញលើដីចំណីឆ្នេរសមុទ្រ ។
- បញ្ឈប់រាល់សកម្មភាពទាំងឡាយណាដែលបានរំលោភយកដីព្រៃ និងដីចំណីឆ្នេរ មានការធ្វើសំណង់គ្រប់ប្រភេទ - ការចាក់ខឿនបេតុង - បោះបង្គោល ឬរៀបដុំថ្មជាដុំៗធ្វើជាខឿនដើម្បីចាក់ដី -ការធ្វើរបងការលប់បំពេញដី ទោះជាបូមដីចាក់ក្តី ឬដឹកដីយកមកចាក់ក្តី លើតំបន់ព្រៃកោងកាងធ្វើជាកម្មសិទ្ធិ ។ល។
- ត្រូវដកហូតមកវិញរាល់ដីព្រៃ និងដីចំណីឆ្នេរជាប់មាត់សមុទ្រ ដែលត្រូវបានរំលោភដោយល្មើសច្បាប់ទុកជាសម្បត្តិរដ្ឋ ។
- ជនល្មើសត្រូវដាំព្រៃកោងកាងឱ្យដូចលក្ខណៈដើមវិញ នៅតំបន់ដែលបានកាប់ព្រៃកោងកាង និងតំបន់ដែលបានចាក់ដីលប់នោះ ហើយតំបន់នោះនឹងត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ។

**ប្រការ ៤:** គណៈកម្មការនេះមានសិទ្ធិសុំកំលាំងអន្តរាគមន៍ពីស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

**ប្រការ៥:** គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការជាជំនួយសំរាប់អនុវត្តការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសតាមបញ្ជារបស់គណៈកម្មការ ។

**ប្រការ ៦:** គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន និងមានលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសំរបសំរួលតំបន់ឆ្នេរ ជាជំនួយការកិច្ចការរដ្ឋបាល ។

**ប្រការ៧:** គណៈកម្មការនេះត្រូវរាយការណ៍អំពីការអនុវត្តរបស់ខ្លួនជូនរាជរដ្ឋាភិបាលឱ្យបានទៀងទាត់ ។

**ប្រការ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរក្រុងកែប អាជ្ញាធរក្រុងព្រះសីហនុ អាជ្ញាធរខេត្តកំពត អាជ្ញាធរខេត្តកោះកុង និងសហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៨០ សហវ.ខាជ

# ប្រកាស

## ស្តីពី

## ការអនុវត្តន៍អាករលើការស្នាក់នៅ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៩ ស្តីពីអាករលើតំលៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សម្រេច :

**ប្រការ ១.-**

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ អាករលើការស្នាក់នៅត្រូវបានកំណត់ និងប្រមូលលើការស្នាក់នៅក្នុងសណ្ឋាគារ ស្ថិតនៅក្នុងរបបកំណត់ពន្ធស្វ័យប្រកាស (របបពិត) និងរបបម៉ៅការ សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាខេត្ត-ក្រុង ។

**ប្រការ ២.-**

សំរាប់គោលដៅនៃប្រកាសនេះ ពាក្យ "សណ្ឋាគារ" សំដៅដល់មូលដ្ឋានផ្តត់ផ្គង់សេវាស្នាក់នៅមានលក្ខណៈជាបន្ទប់ គ្រែ និងមានផ្តល់នូវសម្បទា និងសេវាផ្សេងៗទៀត ទៅតាមប្រភេទនៃមូលដ្ឋានសេវាស្នាក់នៅនីមួយៗ ដូចជា :

ក. **សណ្ឋាគារ** (Hotel) : ជាអាគារមានច្រើនជាន់ ដែលមានទីតាំងស្ថិតនៅក្នុងទីប្រជុំជនជាយក្រុង ឬតំបន់រមណីយដ្ឋានទេសចរណ៍ និងអាចផ្តត់ផ្គង់នូវសេវាពេញលេញដល់ភ្ញៀវ ដូចជា : សេវាស្នាក់នៅ ភោជនីយដ្ឋាន សេវាបំរើអាហារភ្ញៀវដល់បន្ទប់ សេវាបោកគក់ ហាងលក់ទំនិញ និងកន្លែងរៀបចំពិធីជប់លៀង សាលប្រជុំ និងចំណតរថយន្ត ។

ខ. **សណ្ឋាគារអាផាតម៉ិន** (Hotel Apartment) : ជាសណ្ឋាគារមានបន្ទប់ស្នាក់នៅ និងបន្ទប់ស្វ៊ីត (Suite) ដែលបំពាក់គ្រឿងសង្ហារិម សំភារៈបរិក្ខារ និងផ្តត់ផ្គង់នូវសេវាដូចសណ្ឋាគារដែរ ។ បន្ទប់ស្វ៊ីតមានបំពាក់គ្រឿងសំភារៈ ផ្ទះបាយនិងមានបន្ទប់សំរាប់ភ្ញៀវ ។ ភ្ញៀវអាចស្នាក់នៅរយៈពេលខ្លី និងវែង ។

គ. **សណ្ឋាគារស្វ៊ីត** (Suite Hotel) : ជាសណ្ឋាគារដែលមានបន្ទប់ស្នាក់នៅទាំងអស់សុទ្ធតែជាបន្ទប់ស្វ៊ីត ។

ឃ. **សណ្ឋាគាររីសត** (Resort Hotel) : ជាសណ្ឋាគារ ដែលសង់ក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ ស្ថិតនៅឆ្ងាយពីទីប្រជុំជន មានកន្លែងសំរាប់លំហែកាយសំរាកយកខ្យល់អាកាស មានផ្តល់នូវម្ហូបអាហារឬភេសជ្ជៈចំពោះភ្ញៀវដែលមកស្នាក់នៅនិងកំសាន្ត ដូចជា: វាយកូនគោល វាយតេននីស ស្ទូចត្រី ជិះសេះ ។ល។ តំលៃបន្ទប់អាចគិតរួមបញ្ចូលទាំងអាហារ ។

ង. **ម៉ូតែល** (Motel) : ជាអាគារមានមួយ ឬពីរជាន់ ស្ថិតនៅតំបន់ជាយក្រុង ឬតាមបណ្តោយផ្លូវសំខាន់ៗ ផ្តល់នូវសម្បទា និងសេវាមានកំរិតសំរាប់ភ្ញៀវដែលចូលមកស្នាក់នៅ ។ មានភោជនីយដ្ឋានសាមញ្ញតូចមួយ (Snake Bar) សំរាប់ទទួលភ្ញៀវ មានចំណតរថយន្តធំទូលាយ និងអាចមានផ្តត់ផ្គង់នូវសេវាសំរាប់កំសាន្តមួយចំនួន ។

ច. **ឡូជ** (Lodge) : ជាអាគារមានពីរ ឬច្រើនជាន់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់សំរាកកំសាន្តរួមទៅមានបំរើសេវាម្ហូបអាហារ និងភេសជ្ជៈ មានចំណតរថយន្ត ព្រមទាំងផ្គត់ផ្គង់សេវាមានកំរិតដល់ភ្ញៀវដែលចូលមកស្នាក់នៅ ។

ឆ. **ប៊ឹងកាឡូ** (Bungalow): មានអាគារជាភូមិគ្រឹះដាច់ៗពីគ្នា មានមួយជាន់ និងអាច មានច្រើនយូនីត (Unit) ក្នុងអាគារតែមួយ ។ យូនីតនីមួយៗ មានបន្ទប់ដេកមួយ ឬច្រើន មានបន្ទប់ទទួលភ្ញៀវដាច់ដោយឡែក មានផ្ទះបាយ មានចំណតរថយន្ត ព្រមទាំងផ្គត់ផ្គង់សេវាមានកំរិតដល់ភ្ញៀវដែលចូលមកស្នាក់នៅ ។

ជ. **ផ្ទះសំណាក់ ឬផ្ទះភ្ញៀវ** (Guest House) : ជាអាគារដែលមានមួយជាន់ ឬពីរជាន់ បំពាក់សំភារៈ និងផ្គត់ផ្គង់សេវាមានកំរិត អាចទទួលភ្ញៀវបានគ្រប់ប្រភេទ ។

ឈ. **កន្លែងបោះជំរុំទេសចរណ៍** (Tourist Camping): ជាកន្លែងដែលបានបង្កើតឡើង នៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ មានហេដ្ឋារចនាសម្ព័ន្ធ និងសេវាស្នាក់នៅចាំបាច់មួយចំនួន ដើម្បីបំរើភ្ញៀវ ។

ញ. ទីកន្លែងផ្តល់សេវាស្នាក់នៅដ៏ទៃទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល ទោះជាឲ្យ ឬដាក់ឈ្មោះថាជាអ្វីក៏ដោយ ។

ពាក្យ "សណ្ឋាគារ" នេះ មិនរួមបញ្ចូលផ្ទះជួល ឬផ្ទះល្វែងជួលរយៈពេលខ្លី និងរយៈពេលវែងទេ ។

**ប្រការ ៣.-**

អាករលើការស្នាក់នៅ ត្រូវបានកំណត់យកតាមអត្រា ២ ភាគរយ លើថ្លៃបន្ទប់ស្នាក់នៅក្នុងសណ្ឋាគារ ដោយរួមបញ្ចូលទាំងពន្ធ-អាករ និងបន្ទុកសេវាផ្សេងៗ (Service Charge) លើកលែងតែអាករលើការស្នាក់នៅខ្លួនឯង និងអាករលើតម្លៃបន្ថែម ។ ម្ចាស់សណ្ឋាគារ ឬអ្នកតំណាងមានភារកិច្ចប្រមូលប្រាក់អាករនេះពីភ្ញៀវ និងបង់ជូនរដ្ឋបាលសារពើពន្ធ ។

**ប្រការ ៤.-**

១. វិធាននៃការបង់ប្រាក់អាករត្រូវបានកំណត់ដូចខាងក្រោម :

- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់អាករប្រចាំខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្គត់ផ្គង់ ។
- អ្នកជាប់ពន្ធតាមរបបម៉ៅការ ត្រូវបង់ប្រាក់អាករនេះជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្គត់ផ្គង់ ។

២. ពេលផ្គត់ផ្គង់សេវាស្នាក់នៅត្រូវបានកំណត់ដូចខាងក្រោម :

ក. អាករលើការស្នាក់នៅត្រូវដល់កំណត់ និងត្រូវបង់នៅពេលផ្គត់ផ្គង់សេវាស្នាក់នៅ ។ ការផ្គត់ផ្គង់សេវាស្នាក់នៅ គឺជាពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញ

វិក្កយបត្រ ឬជាពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាងបានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះ ត្រូវបានចេញមុនពេលដែលម្ចាស់សណ្ឋាគារ ឬអ្នកតំណាង ត្រូវចេញវិក្កយបត្រ ។ ម្ចាស់សណ្ឋាគារ ឬអ្នកតំណាងត្រូវចេញវិក្កយបត្រអាករ លើការស្នាក់នៅយ៉ាងយឺតបំផុត ៧ថ្ងៃ ក្រោយពីការបំពេញសេវាស្នាក់នៅត្រូវបញ្ចប់ឬក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើង មុនការបំពេញសេវាលើការស្នាក់នៅ ។

ខ. ក្នុងករណីសេវាលើការស្នាក់នៅ ត្រូវបានផ្តល់ផ្តល់ក្នុងលក្ខណៈជាអំណោយ ពេលផ្តល់ផ្តល់គឺជាពេលដែលសេវាផ្តល់ផ្តល់ត្រូវបានបំពេញរួចរាល់ ។

**ប្រការ ៥.-**

បទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ត្រូវយកមកអនុវត្តចំពោះអាករលើការស្នាក់នៅនេះ។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥ នេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥

**គាត ឈន់**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ

# សារាចរណែនាំ

## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា ខេត្ត ក្រុងឆ្នាំ ២០០៦

យោងសារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦

យោងប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកាខេត្ត ក្រុង ឆ្នាំ ២០០៦ ដូចតទៅ ៖

### I. ការរៀបចំចំណូលថវិកា :

1. ការគិតគូរចំណូលចរន្តរបស់ថវិកាខេត្ត ក្រុង អាស្រ័យទៅលើប្រភពនៃផលិតផល ឬ ផលទុន ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ។

ផ្អែកតាមប្រភពធនធានខាងលើនេះ អភិបាលខេត្ត ក្រុងត្រូវរៀបចំនូវគំរោងចំណូលថវិការបស់ខេត្ត ក្រុងសាមីដូចតទៅ ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖
  - \+ លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - \+ ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - \+ ប៉ាន់ស្មានលើការវិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  - \+ ការប្រែប្រួលដែលអាចកើតមានឡើង ឬត្រូវពិនិត្យពិចារណាលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
  - \+ ចំណូលដែលសង្ឃឹមថាបានមកពីការបង្កើតពន្ធថ្មី (ករណីមានគោលនយោបាយថ្មី) ។
- ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានផលទុន ដូចជាកិច្ចសន្យាជួល សេវាកម្ម។ល។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសំរេចបាននៃឆ្នាំកន្លងមក និងការវិវឌ្ឍន៍នៃសេដ្ឋកិច្ច ។

ចំពោះនីតិវិធី គឺអភិបាលខេត្ត ក្រុង ត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាខាពន្ធដារ និងមន្ទីរជំនាញដែលពាក់ព័ន្ធ ក្នុងការប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ សំរាប់ថវិកាខេត្ត ក្រុង ដើម្បីមកចូលរួមពិភាក្សាគិតគូររៀបចំជាគំរោងចំណូលសរុប ទៅតាមតារាងឧបសម្ព័ន្ធទី១ ដែលជូនភ្ជាប់មកជាមួយនេះ ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិកាខេត្ត ក្រុង ក្នុងករណីដែលមាន គឺត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុងគំរោងចំណូល ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេសដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង រួចហើយនោះ ។

## II. ការរៀបចំចំណាយថវិកា

3. ខេត្ត ក្រុងត្រូវរៀបចំនូវគំរោងចំណាយសំរាប់រាល់សកម្មភាពសេវាទាំងអស់ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។ របៀបគិតគូរនូវតំរូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗដោយច្បាស់លាស់ និងដោយផ្អែកទៅ លើកត្តានានា ដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះ ដូចជា តារាងបុគ្គលិក បញ្ជីព័ទ៌ស្នាទបរិមាណ តំលៃ សម្ភារៈ ឬសេវា... ។ ចំពោះសកម្មភាពមួយចំនួនទាមទារអោយមានបង្កើតចម្មនិយាមសមស្រប ដូចជា ចំណាយជួសជុលក្នុងមួយម៉ែត្រការ៉េ ចំនួនទឹកប្រាក់ចាំបាច់ សំរាប់ផ្ទៃក្រឡាណាមួយ ការប្រើប្រាស់គ្រឿងចក្រគិតជា ប្រេងឥន្ធនៈ ការសិកវិចនៃសំបកកង់រថយន្តគិតជាគីឡូម៉ែត្រជាដើម ។ ចំពោះសម្ភារៈបរិក្ខារដែលប្រើប្រាស់ជាប្រចាំ ត្រូវគិតគូរដោយផ្អែកតាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគនៃបណ្តាឆ្នាំកន្លងមក ។ ចំណែកឯ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុងនិងក្រៅប្រទេស) និងប្រាក់ឈ្នួលផ្ទះ ទឹកភ្លើងរបស់អភិបាល អភិបាលរងគ្រប់ខេត្ត ក្រុងត្រូវអនុវត្តផ្អែកលើមូលដ្ឋានអនុក្រឹត្យលេខ ៦២ អនក្របក ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការទីប្រឹក្សាព្រមទាំងមន្ត្រីរាជការស៊ីវិល និងកងកំលាំងប្រដាប់អាវុធចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ ។

គំរោងចំណាយទាំងអស់របស់ថវិកាខេត្ត ក្រុង ត្រូវបានសរុបនៅក្នុងតារាង ឧបសម្ព័ន្ធទី២ ដែលជូនភ្ជាប់មកជាមួយនេះ ។

4. ជាទូទៅ សំណើចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយ តាមជំពូក ប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ដើម្បីបង្ហាញអោយឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវ ហ្មត់ចត់ និងសមហេតុផល ។ លិខិតយុត្តិការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

5. សារាចរណែនាំនេះ ក៏មានភ្ជាប់ជាមួយនូវសលាកប័ត្រគំរូមួយចំនួនសំរាប់បំពេញនូវឥណទាន ដែលត្រូវស្នើសុំទៅតាមមុខចំណាយនីមួយៗ ។ សលាកប័ត្រទាំងអស់នេះ ត្រូវបានអង្គភាពនានារបស់ខេត្ត ក្រុង ប្រើប្រាស់សំរាប់ផ្តល់នូវពត៌មានបន្ថែម ទៅលើការស្នើសុំឥណទានរបស់ខ្លួន ។

### II.1 ការរៀបចំគំរោងចំណាយចរន្ត

6. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ÷

## ប្រភេទ ១ : មធ្យោបាយសេវា

### ជំពូក១០ : ប្រាក់បៀវត្ស និង ប្រាក់បំណាច់

7. ចំណាយសំរាប់បុគ្គលិកត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ចំណាយលើជំពូកនេះ ត្រូវបានចាត់ទុកជា

ចេញដោយក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ មន្ត្រីរាជការដែលមានដាក់ស្នែងក្នុងឆ្នាំ ២០០៥ មន្ត្រីរាជការដែលចូលនិវត្តន៍ត្រូវផ្ទេរចេញពីក្របខ័ណ្ឌ និងមន្ត្រីមរណៈដែលត្រូវកាត់បន្ថយពីអង្គភាពរបស់ខ្លួន នៅឆ្នាំ ២០០៦ ខាងមុខនេះរាជរដ្ឋាភិបាលនិងបង្កើនប្រាក់បៀវត្សមូលដ្ឋានចំនួន ១៥ភាគរយ ដែលនិងប្រើឥណទានមូលនិធិបម្រុង។ ចំពោះគំរោង ចំណាយអំពីប្រាក់បំណាច់បុគ្គលិកអណ្តែត និងគំរោងចំណាយអំពីលាភការភ្នាក់ ងារជាប់កិច្ចសន្យា គឺចាំបាច់ត្រូវតែមានសេចក្តីសំរេចអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្របខ័ណ្ឌឥណទានដែលបានពិភាក្សា រួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ក. បុគ្គលិកដែលកំពុងមានក្នុងពេលបច្ចុប្បន្ន

8. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមនិវាទខេត្ត ក្រុង ត្រូវបូកសរុបនៅក្នុងសលាកប័ត្រ១ ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលខេត្ត ក្រុងមាន ។

9. សលាកប័ត្រ១នេះ គឺសំរាប់សរុបបុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនិងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ) ។

10. ខេត្ត ក្រុងត្រូវលំអិតចំនួនបុគ្គលិកទៅតាមស្រុក ខ័ណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមនិវាទរបស់ខ្លួន ។

## ខ. ការជ្រើសរើសបុគ្គលិកថ្មី

11. អភិបាលខេត្ត ក្រុង តែងតាំងបុគ្គលិកខេត្ត ក្រុងក្នុងក្របខ័ណ្ឌនៃថវិការបស់ខេត្ត ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋានដោយឡែកដែលមានជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤, ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមកាតព្វកិច្ចរបស់ភ្នាក់ងារសាធារណៈទាំងអស់ ។ ខេត្ត ក្រុងអាចសំរេចជ្រើសរើសអោយចូលធ្វើការចំពោះបុគ្គលិកប្រភេទ "គ" និង"ឃ" ក្នុងករណីដែលចាំបាច់បំផុតបន្ទាប់ពីបានប្រើប្រាស់អោយអស់លទ្ធភាពនូវមន្ត្រីរាជការដែលមានស្រាប់ ប្រការនេះគឺជាគោលការណ៍រួមតែប៉ុណ្ណោះ។ បច្ចុប្បន្នក្នុងពេលដែលរាជរដ្ឋាភិបាលកំពុងដំណើរការ កែទំរង់រដ្ឋបាលសាធារណៈនិងធ្វើវិចារណកម្មលើចំនួនក្របខ័ណ្ឌមន្ត្រីរាជការនោះ ខេត្ត ក្រុងមិនត្រូវបានអនុញ្ញាតអោយជ្រើសរើសបុគ្គលិកថ្មីទេ ។

## ជំពូក១១ : ដំណើរការរដ្ឋបាល សម្ភារៈនិងការជួសជុលតូច

12. ជំពូក១១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់ខេត្ត ក្រុង ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបានហ្មត់ចត់ និងសន្សំសំចៃបំផុត ក្នុងឆ្នាំ២០០៦ ផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈចំណាយឥណទានផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិត៩៣ភាគរយនៃឆ្នាំ ២០០៥ តែប៉ុណ្ណោះ ។ ដោយឡែកការកាត់បន្ថយចំនួន ៧ភាគរយនេះ គឺបង្ហាញអោយឃើញអំពីភាពហ្មឹងម៉ាត់របស់រាជរដ្ឋាភិបាលក្នុងការសន្សំសំចៃថវិកាទុកសំរាប់ដោះរំលស់បំណុលសាច់ប្រាក់កក្ស្ទះនៅធនាគារជាតិ និងសំរាប់បង្កើនចំណាយវិនិយោគសាធារណៈនិងចំណាយលើការថែទាំនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសផ្លូវស្ពាន និងប្រព័ន្ធស្រោចស្រព។

មួយផ្នែកទៀតជាឥណទានសំរាប់បំរើដល់គុណប្រយោជន៍របស់ខេត្ត ក្រុង ( ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤ ) ក្នុងការរៀបចំមូលដ្ឋានសំភារៈនៃសេវាសាធារណៈ និងការអភិវឌ្ឍន៍របស់ខេត្ត ក្រុង ។ ផ្អែកលើផែនការអភិវឌ្ឍន៍ខេត្ត ក្រុងរបស់ក្រសួងមហាផ្ទៃ ខេត្ត ក្រុងនីមួយៗ ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយអាទិភាពនៃគំរោងចំណាយលំអិតអំពីការងារជាគុណប្រយោជន៍របស់ខេត្ត ក្រុង ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សានៃគំរោងថវិកាប្រចាំឆ្នាំ ។សលាកបត្រយុត្តិការដែលមានខាងក្រោមនេះ សំរាប់បង្ហាញនូវខ្ទង់ចំណាយសំខាន់ៗ ក្នុងជំពូក១១ របស់អង្គភាពនីមួយៗដែលមានការពាក់ព័ន្ធ ។

- អសង្ហារិម (សលាកបត្រ២) : ឥណទានត្រូវបានបែងចែកតាមកន្លែងដែលប្រើប្រាស់គ្រឿងអសង្ហារិម ដូចជា កន្លែងរដ្ឋបាល ឬនិវាសនដ្ឋាន និងតាមប្រភេទចំណាយ ដូចជាការថែទាំ ការប្រើប្រាស់ទឹក អគ្គិសនីជាដើម ។
- ចលនវត្ថុ សម្ភារៈ (សលាកបត្រ៣) : គប្បីបែងចែកដាច់ពីគ្នារវាងការទិញនិងការថែទាំ ។ ចំពោះសម្ភារៈការិយាល័យមានខ្ទង់មួយសំរាប់បំពេញក្នុងសលាកបត្រនេះ ។
- រថយន្ត (សលាកបត្រ៤) : ជាទូទៅ ចំណាយលើការប្រើប្រាស់និងថែទាំរថយន្ត មានទំហំធំធេងណាស់បើប្រៀបធៀបនឹងប្រភេទចំណាយឯទៀត ។ ដូច្នេះអង្គភាពនីមួយៗត្រូវខិតខំយ៉ាងណា ដើម្បីខ្ទប់ចំណាយនេះកុំអោយលើសពីកំរិតដែលសមស្រប ។ ការធ្វើយុត្តិកម្មឥណទាន ត្រូវតែមានភាពច្បាស់លាស់ និងត្រូវផ្អែកទៅលើគុណភាពរថយន្ត ម៉ាករថយន្ត ផ្លាកលេខ ឆ្នាំទិញ ចម្ងាយផ្លូវដែលបានបើកបរគិតជាគីឡូម៉ែត្រ រីឯការគ្រោងឥណទានអនុញ្ញាតអោយគ្រោង បានចំពោះតែរថយន្តស្ថិតក្នុងបញ្ជីសារពើភ័ណ្ឌរបស់រដ្ឋតែប៉ុណ្ណោះ ។ ដោយហេតុនេះហើយត្រូវបែងចែកឥណទានដែលស្នើសុំ ទៅតាមឥណទានសំរាប់ការថែទាំ សំរាប់ប្រេងឥន្ធនៈ និងសំរាប់ប្រេងរំអិល ។
- សោហ៊ុយធ្វើដំណើរ (សលាកបត្រ៥) : គឺជាប្រាក់សំរាប់ធ្វើដំណើរ របស់មន្ត្រីរាជការចេញទៅបំពេញបេសកកម្ម ។ ប្រការនេះ គឺត្រូវបែងចែកអោយដាច់ពីគ្នាទៅតាមប្រភេទបេសកកម្ម ដូចដែលបានចែងក្នុងអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ មេសា ឆ្នាំ ២០០៤ ។
- ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ដូចជាចំណាយបំភ្លឺសាធារណៈ ការប្រមូលសំរាម ថែទាំផ្លូវថ្នល់ សួនច្បារសាធារណៈ ប្រឡាយ លូទឹកជាដើម ត្រូវមានគំរោងលំអិតសំរាប់មុខសញ្ញានីមួយៗ និងត្រូវបញ្ជាក់នូវទីតាំង ភូមិ ឃុំ សង្កាត់ និងស្រុក ខ័ណ្ឌអោយបានច្បាស់លាស់ ។
- ចំណាយទទួលភ្ញៀវ ទស្សនៈកិច្ចនិងប្រជុំ ត្រូវគ្រោងអោយស្ថិតនៅក្នុងកំរិតមួយសមស្របដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់និងមិនធ្វើអោយបាត់តុល្យភាពថវិកា ។ ចំពោះខេត្ត ក្រុង ដែលទទួលការឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ ត្រូវគ្រោងចំណាយប្រភេទនេះក្នុងកំរិតទាបបំផុត ។

**13.** សលាកបត្រទាំងប៉ុន្មាននេះ មិនអាចប្រើប្រាស់ជាលិខិតយុត្តិការចាំបាច់បានគ្រប់គ្រាន់ទេ ដោយគ្រាន់តែធ្វើជាមូលដ្ឋានសំរាប់រៀបចំគំរោងថវិកាអោយស្ថិតក្នុងកំរិតមួយសមស្រប នៅក្នុងការគិតគូរនិងឆ្លើយតបទៅនឹងគោលដៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈតែប៉ុណ្ណោះ ។ សលាកបត្រមានច្រើនប្រភេទបែបនេះ គឺសំរាប់ធានាអោយបាននូវសុពលភាពនៃគំរោងចំណាយ និងភ្ជាប់ជាមួយនូវសំណុំឯកសារ ដើម្បីបង្ហាញនូវថវិកាជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**14.** ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប ។ ម្យ៉ាងទៀត ខេត្ត ក្រុងមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសំរាប់ចំណាយទូរស័ព្ទ អគ្គីសនី ទឹក ខេត្ត ក្រុងត្រូវគ្រោងអោយបានគ្រប់គ្រាន់សំរាប់តំរូវក្នុងឆ្នាំ និងការសងបំណុល ក្នុងករណីដែលខេត្ត ក្រុងគ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងថវិការបស់ខេត្ត ក្រុង និងដាក់កម្មវិធីចំណាយសំរាប់ទូទាត់ជូនខេត្ត ក្រុងដោយស្វ័យប្រវត្តិ ។

**15.** ចំពោះឥណទានសំរាប់ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង (ជំពូក ១១ ប្រការ ០១ កថាខ័ណ្ឌ ១៤) ខេត្ត ក្រុងត្រូវគ្រោងឥណទានដោយលំអិតតាមវាក្យខណ្ឌនីមួយៗ ហើយក្នុងវាក្យខណ្ឌនីមួយៗ ក៏ត្រូវមានគំរោងលំអិតតាមការដ្ឋាននីមួយៗដោយមានបញ្ជាក់អំពីបញ្ជីថ្លៃតម្លៃ និងទីតាំងច្បាស់លាស់សំរាប់យកមកពិភាក្សាសំរេចជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពេលតែមួយនៃការពិភាក្សាថវិកាប្រចាំឆ្នាំ ។

### ជំពូក១២ : ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល

**16.** ចំណាយក្នុងជំពូកនេះសំរាប់ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល ដែលខេត្ត ក្រុងបង្កើតឡើងហើយក៏ផ្តល់សេវាសាធារណៈ ដែលទទួលបានពុំអាចរ៉ាប់រងបាននូវរាល់ការចំណាយចាំបាច់ ។

## ប្រភេទ ៣ : ចំណាយអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

**17.** ចំពោះចំណាយប្រភេទនេះ ត្រូវចែងលំអិតអោយបានច្បាស់លាស់ នូវគោលដៅដែលត្រូវសំរេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះអោយបានហ្មត់ចត់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន ។

## ប្រភេទ ៤ : ចំណាយផ្សេងៗ និងចំណាយមិនបានគ្រោងទុក

**18.** ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសំរាប់ចំណាយចៃដន្យ ដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត ។ សំរាប់ឆ្នាំថវិកា២០០៦ប្រភេទឥណទាន គឺអនុញ្ញាតអោយគ្រោងចំនួន ៣ ភាគរយ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញអោយជំពូកដទៃទៀត ដែលជាតំរូវការចំណាយចៃដន្យកើតមានឡើងដោយយថាហេតុ ។

**19.** ចំណាយជាមូលធន គឺជាចំណាយសំរាប់ធ្វើហិរញ្ញប្បទានចំពោះគំរោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុននិងសំដៅធ្វើអោយសំរេចតាមគោលដៅដែលបានដាក់ចេញ ។

**20.** គំរោងវិនិយោគរបស់ខេត្ត ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងបានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការ អោយគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិកាខេត្ត ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងមានចំណូលជាមូលធនផ្ទៃក្នុងខេត្ត ក្រុងផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬ គំរោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលឬម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង ដើម្បីកត់ត្រាចូលទៅក្នុងគំរោងថវិការបស់ខេត្ត ក្រុង ។ ទន្ទឹមនឹងនេះក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគំរោង ដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

## III. គំរោងចំណូល ចំណាយសរុប

**21.** គំរោងចំណូល ចំណាយថវិការបស់ខេត្ត ក្រុងនីមួយៗដែលបានគិតគូរ រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗផង ។ គំរោងចំណូលចំណាយនេះ ត្រូវរៀបចំអោយមានតុល្យភាពពិតប្រាកដ ហើយត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកាមួយ ដែលមានប្រភពធនធានរួមផ្សំឡើងដោយការឧបត្ថម្ភមានកំរិតកំណត់ពីថវិការដ្ឋ និងលទ្ធភាពពិតប្រាកដនៃការប្រមូលចំណូលផ្ទាល់របស់ខេត្ត ក្រុង ។

**22.** ចំពោះខេត្តបាត់ដំបង និងខេត្តសៀមរាប គំរោងចំណាយត្រូវភ្ជាប់មកជាមួយនូវគំរោងចំណាយរបស់ស្រុកដំបងបាត់ និងស្រុកសៀមរាប ដែលខេត្តត្រូវបែងចែក (តាមរួមមន្តបែងចែកចំណាយឆ្នាំ ២០០៥) និងធ្វើប្រតិភូកម្មជូនស្រុក ដើម្បីអនុវត្តជាអាណាប័កផ្ទេរសិទ្ធិ ។

**23.** គំរោងចំណូល ចំណាយថវិកាខេត្ត ក្រុងត្រូវបានកែសំរួលបំពេញបន្ថែមតាមទំរង់ដូចមានភ្ជាប់មកជាមួយ និងសារាចរណែនាំនេះ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលខេត្ត ក្រុងទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង
  (ដើម្បីមុខការ)
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ឧបសម្ព័ន្ធទី១

# ការគ្រប់គ្រងឆ្នាំ ២០០៦

## តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | [illegible] | ការរាយមុខចំណូល (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៥ | | | គំរោងឆ្នាំ ២០០៦ |
|---|---|---|---|---|---|---|---|---|
| | | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | | |

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
អ្នកធ្វើតារាង

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី .... ខែ ...... ឆ្នាំ ២០០៥
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# ការគ្រប់គ្រងឆ្នាំ ២០០៦

## តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៥ | | | គំរោងឆ្នាំ ២០០៦ |
|---|---|---|---|---|---|---|---|---|
| | | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | **ប្រភេទទី១: ពន្ធ និង អាករ** | | | | |
| 10 | | | | **ជំពូក១០: ពន្ធ និង អាករ** | | | | |
| | 08 | | | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | | | | |
| 11 | | | | **ជំពូក១១: ពន្ធលើបេតិកភ័ណ្ឌ** | | | | |
| | 01 | | | ពន្ធប្រថាប់ត្រា | | | | |
| 12 | | | | **ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវាកម្ម** | | | | |
| | 03 | | | ពន្ធពាណិជ្ជកម្ម | | | | |
| | 04 | 02 | | អាករពិសេស: របបនៃការនាំចូល | | | | |
| | 05 | | | ពន្ធសត្តឃាដ | | | | |
| | 08 | | | អាករលើតម្លៃបន្ថែម: របបនាំចូល | | | | |
| | | 01 | | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | 02 | | សហគ្រាសដទៃទៀត | | | | |
| | 06 | | | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ | | | | |
| | 07 | | | អាករសំរាប់បំភ្លឺសាធារណៈ | | | | |
| | 09 | | | អាករលើការស្នាក់នៅ | | | | |
| 13 | | | | **ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | | | | |
| | 01 | | | ពន្ធ និង អាករគយពីការនាំចូល | | | | |
| | | 01 | | ពន្ធគយពីការនាំចូល | | | | |
| | | 03 | | កំរៃយកមុនលើការងារគយក្នុងការនាំចូល | | | | |
| | | 04 | | ពន្ធគយលើផលិតផលប្រេងកាត | | | | |
| | | 05 | | អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវថ្នល់ | | | | |
| | 03 | | | ការផាកពិន័យរបស់គយ | | | | |

**បញ្ជាក់:** ចំពោះខេត្ត ក្រុងទាំងឡាយណាដែលមានដូចមុខចំណូលខាងលើ ត្រូវគ្រោងបញ្ចូលទៅក្នុងតារាង ឧបសម្ព័ន្ធទី ១

